# LYNN PUBLIC SCHOOLS

**James Leo McGuinness អាគាររដ្ឋបាល – 100 Bennett Street, Lynn, MA 01905**

**ទូរស័ព្ទ (781) 593-1680 ~ ទូរសារ (781) 477-7487**

***Patrick A. Tutwiler, PhD***
*អគ្គនាយកសាលា*

ថ្ងៃទី26 ខែមីនា ឆ្នាំ2021

ជូនចំពោះក្រុមគ្រួសារ Lynn Public Schools

ខ្ញុំសរសេរដើម្បីធ្វើបច្ចុប្បន្នភាពលើផែនការក្នុងការពង្រីកការសិក្សាដោយផ្ទាល់។ កាលពីសប្តាហ៍មុន អ្នកទទួលបានការកំណត់ពេលវេលាជាមួយកាលបរិច្ឆេទជាក់លាក់ សម្រាប់សិស្សដើម្បីត្រឡប់មកវិញ។ ចាប់តាំងពីពេលនោះមក យើងបានប្រមូលមតិរបស់អ្នកនិងកែលម្អផែនការរបស់យើង។ មានការផ្លាស់ប្តូរពីរលើផែនការរបស់យើង ដែលខ្ញុំសង្ឃឹមថានឹងត្រូវបានស្វាគមន៍។

ជាបឋម សូមក្រើនរំលឹកដល់ក្រុមគ្រួសារទាំងអស់ថា ដោយអនុលោមតាមការណែនាំរបស់នាយកដ្ឋានបឋមនិងមធ្យមសិក្សា គ្រួសារអាចជ្រើសរើសបន្តការរៀនពីចម្ងាយសម្រាប់រយៈពេលនៅសល់នៃឆ្នាំសិក្សា។ សិស្សដែលជ្រើសរើសបន្តការរៀនពីចម្ងាយនឹងបន្តទទួលបានការណែនាំនិងជំនួយបន្តផ្ទាល់។ ជម្រើសក្នុងការបន្តរៀនពីចម្ងាយនឹងមិនប៉ះពាល់ដល់សមត្ថភាពរបស់សិស្ស ដែលត្រូវបានតម្លើងទៅថ្នាក់បន្ទាប់ ឬបញ្ចប់ការសិក្សាពីវិទ្យាល័យទេ។ សម្រាប់ក្រុមគ្រួសារដែលបានជ្រើសរើសការមករៀនដោយផ្ទាល់សម្រាប់រយៈពេលនៅសល់នៃឆ្នាំសិក្សា ខ្ញុំសូមចែករំលែកនូវព័ត៌មានថ្មីៗដូចខាងក្រោម៖

- សាលាមត្តេយ្យ (ព្រឹក/ល្ងាច) ទី1 និងទី2 នឹងចាប់ផ្តើមបង្រៀនរយៈពេល **ប្រាំ**ថ្ងៃចាប់ពីថ្ងៃទី 5 ខែមេសា។
- ថ្នាក់ទី 3-5 នឹងចាប់ផ្តើមបង្រៀនរយៈពេល **ប្រាំ**ថ្ងៃចាប់ពីថ្ងៃទី12 ខែមេសា។
- មិនមានការផ្លាស់ប្តូរពេលវេលាសម្រាប់មធ្យមសិក្សានិងវិទ្យាល័យដើម្បីពង្រីកការសិក្សាដោយផ្ទាល់នោះទេ។

ការផ្លាស់ប្តូរការកំណត់ពេលវេលា ដើម្បីចាប់ផ្តើមរៀនដោយផ្ទាល់រយៈពេលប្រាំថ្ងៃសម្រាប់សិស្សបឋមទាំងអស់គឺជាអ្វីដែលយើងរំភើប។ វាក៏ជាមូលហេតុសម្រាប់ការធ្វើផែនការនិងការរៀបចំបន្ថែមដែលបន្តដោយយកចិត្តទុកដាក់។ អ្នកអាចពឹងផ្អែកលើការប្រាស្រ័យទាក់ទងបន្ថែមដោយផ្ទាល់ពីសាលារៀនរបស់សិស្សអ្នក។ ខ្ញុំចង់ឱ្យអ្នកទទួលបានព័ត៌មាននេះអោយបានលឿនតាមដែលអាចធ្វើទៅបាន ដើម្បីឱ្យអ្នកមានគម្រោងត្រឹមត្រូវ។ ដើម្បីភាពងាយស្រួលរបស់អ្នក ខ្ញុំបានបិទភ្ជាប់ក្រាហ្វិចជាមួយបន្ទាត់ពេលវេលាសម្រាប់សាលារៀនទាំងអស់ក៏ដូចជាម៉ោង។ ដូចរាល់ដង សូមទាក់ទងសាលារៀនរបស់កូនអ្នកជាមួយនឹងសំណួរឬកង្វល់ផ្សេងៗ។

ដោយក្តីគោរព

Patrick Tutwiler, PhD

| ការកំណត់ពេលវេលាសម្រាប់ការផ្លាស់ប្តូរមករៀនដោយផ្ទាល់ - *បានធ្វើបច្ចុប្បន្នភាព* | |
|---|---|
| **បឋមសិក្សា** | |
| **កាលបរិច្ឆេទ** | **ថ្នាក់ / ក្រុម** |
| **មេសា** | |
| ថ្ងៃទី1 ខែមេសា | ថ្នាក់មត្តេយ្យ ព្រឹក/ល្ងាច |
| កម្មវិធីទាំងអស់ខាងក្រោមនេះនឹងចូលរួមរៀនដោយផ្ទាល់**ប្រាំ**ថ្ងៃក្នុងមួយសប្តាហ៍ លើកលែងតែមានការណែនាំផ្សេងទៀត | |
| ថ្ងៃទី5 ខែមេសា | ថ្នាក់បឋម 1,2<br>ថ្នាក់មត្តេយ្យ ព្រឹក/ល្ងាច |
| ថ្ងៃទី7 ខែមេសា | គ្រប់ថ្នាក់ Fallon |
| ថ្ងៃទី12 ខែមេសា | ថ្នាក់ទី 3-5 |

| ការកំណត់ពេលវេលាសម្រាប់ការផ្លាស់ប្តូរមករៀនដោយផ្ទាល់ - *មិនមានភាពផ្លាស់ប្តូរ* | |
|---|---|
| **មធ្យមសិក្សានិងវិទ្យាល័យ** | |
| **កាលបរិច្ឆេទ** | **ថ្នាក់ / ក្រុម** |
| **មេសា** | |
| កម្មវិធីទាំងអស់ខាងក្រោមនេះនឹងចូលរួមរៀនដោយផ្ទាល់**ពីរ**ថ្ងៃក្នុងមួយសប្តាហ៍ លើកលែងតែមានការណែនាំផ្សេងទៀត | |
| ថ្ងៃទី5 ខែមេសា | LVTI Shop Rotations – ថ្នាក់ទី 11 |
| ថ្ងៃទី12 ខែមេសា | ថ្នាក់ទី 6-8 និង 9,10<br>LVTI Shop ថ្នាក់ទី 9,12<br>LVTI Core Academic ថ្នាក់ទី 10,11<br>គ្រប់ថ្នាក់ Fecteau-Leary |
| **ឧសភា** | |
| ថ្ងៃទី3 ខែឧសភា | ថ្នាក់ទី 11, 12 |
| កម្មវិធីទាំងអស់ខាងក្រោមនេះនឹងចូលរួមរៀនដោយផ្ទាល់**ប្រាំ**ថ្ងៃក្នុងមួយសប្តាហ៍ លើកលែងតែមានការណែនាំផ្សេងទៀត | |
| ថ្ងៃទី10 ខែឧសភា | ថ្នាក់មធ្យមសិក្សាទាំងអស់ |

| កាលវិភាគសាលា | | |
|---|---|---|
| **បឋមសិក្សា** | **មធ្យមសិក្សា** | **វិទ្យាល័យ** |
| <u>បឋមសិក្សាពេលលឿន៖ 7:45 - 12:45</u><br>(Callahan, Cubbies Den (LVTI), Drewicz, Fallon, Ford, Harrington, Ingalls, Sisson, Washington)<br>Pre-K និងសាលាមត្តេយ្យ៖<br>**ព្រឹក**<br>7:45ព្រឹក – 10:00ព្រឹក<br>**ថ្ងៃ**<br>11:30ព្រឹក – 1:45ថ្ងៃ<br><u>បឋមសិក្សាពេលយឺត៖ 8:15 - 1:15</u><br>(Aborn, Brickett, Cobbet, Connery, Hood, Lincoln Thomson, Lynn Woods, Sewell Anderson, Shoemaker, Tracy)<br>Pre-K និងសាលាមត្តេយ្យ៖<br>**ព្រឹក**<br>8:15ព្រឹក – 10:30ព្រឹក<br>**ថ្ងៃ**<br>12:00ថ្ងៃ – 2:15ថ្ងៃ | Breed៖ 7:30 - 1:00<br>Marshall៖ 7:45 - 1:15<br>Pickering៖ 7:45 - 1:15 | អង់គ្លេស, Classical, LVTI និង<br>Fecteau-Leary៖<br>7:45 - 1:30 |